**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧១៦ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការកាត់ដីសរុបទំហំ ១.២៥៨ ហិកតា ដែលក្នុងនោះ (១) កាត់ចេញពីក្រុមហ៊ុនហ្គោលហ្វៀសិន (២)ពីក្រុមហ៊ុនមេគង្គ និង(៣) ពីដែនជម្រកសត្វព្រៃបឹងពែរ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤១៧ គ្រួសារ និងស្នើសុំផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៤០៨ គ្រួសារ លើ ៦១៦ ក្បាលដី ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្ដែង នៅស្រុកប្រាសាទសំបូរ និងស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១២/១០០៨ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៦១១ ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ១.២៥៨ ហិកតា ដែលក្នុងនោះ (១) ទំហំ ៥៥៨ ហិកតា កាត់ចេញពីក្រុមហ៊ុនហ្គោលហ្វៃសិន (២) ទំហំ ២៥២ ហិកតា ពីក្រុមហ៊ុនមេគង្គ និង (៣) ទំហំ ៤៤៨ ហិកតា ពីដែនជម្រកសត្វបឹងពែរ តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ដើម្បីធ្វើអនុប្រយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅខេត្តកំពង់ធំ ដែលស្ថិតនៅក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

១. ផ្ទៃដីទំហំ ៥៥៨ ហិកតា កាត់ចេញពីក្រុមហ៊ុន ហ្គោលហ្វៃសិន សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិស្រើង ឃុំស្រើង ស្រុកប្រាសាទសំបូរ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ។

២. ផ្ទៃដីសរុបទំហំ ៣៧៥ ហិកតា ដែលក្នុងនោះ កាត់ចេញពីក្រុមហ៊ុនមេគង្គ ទំហំ ១៧៨ ហិកតា និងពីដែនជម្រកសត្វព្រៃបឹងពែរ ទំហំ ១៩៧ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

៣. ផ្ទៃដីទំហំ ៣២៥ ហិកតា ដែលក្នុងនោះ កាត់ចេញពីក្រុមហ៊ុន មេគង្គ ទំហំ ៧៤ ហិកតា និងពីដែនជម្រកសត្វព្រៃបឹងពែរ ទំហំ ២៥១ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូន

ប្រជាពលរដ្ឋ នៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទី ឧបសម្ព័ន្ធ(៣) នៃអនុក្រឹត្យនេះ។

**មាត្រា ២.**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៤១៧ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

១. ផ្ទៃដីកាត់ចេញពីក្រុមហ៊ុន ហ្គោលហ្វៀសិន ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១០៨ គ្រួសារ នៅភូមិស្រើង ឃុំស្រើង ស្រុកប្រាសាទសំបូរ

២. ផ្ទៃដីកាត់ចេញពីក្រុមហ៊ុន មេគង្គ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៩៥ គ្រួសារនិងផ្ទៃដីកាត់ចេញពីដែនជម្រកសត្វព្រៃបឹងពែរ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៧៣ គ្រួសារ នៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក

៣. ផ្ទៃដីកាត់ចេញពីក្រុមហ៊ុនមេគង្គ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៩ គ្រួសារ និងផ្ទៃដីកាត់ចេញពីដែនជម្រកសត្វបឹងពែរ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩៨ គ្រួសារ នៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក។

**មាត្រា ៣ ..**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៤០៨ គ្រួសារ លើក្បាលដីចំនួន ៦១៦ ក្បាលដី នៅភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១០៨ គ្រួសារ លើក្បាលដីចំនួន ១៨៥ ក្បាលដី នៅភូមិស្រើង ឃុំស្រើង ស្រុកប្រាសាទសំបូរ
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១៦៨ គ្រួសារ លើក្បាលដីចំនួន ២៤៣ ក្បាលដី នៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១៣២ គ្រួសារ លើក្បាលដីចំនួន ១៨៨ ក្បាលដី នៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្ក។

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*